ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ភ្នំពេញ ថ្ងៃទី ០៧ ខែឧសភា ឆ្នាំ២០១៧

# សេចក្តីប្រកាសព័ត៌មាន

## ស្តីពី

# កិច្ចប្រជុំស្តីពីការគ្រប់គ្រងប្រមូលពន្ធប្រថាប់ត្រា របស់អគ្គនាយកដ្ឋានពន្ធដារ




© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ

នាវេលាម៉ោង ០៩:០០ នាទីព្រឹក ថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ២០១៧ នៅសាលាជាតិពន្ធដារ នៃអគ្គនាយកដ្ឋានពន្ធដារ មានរៀបចំកិច្ចប្រជុំស្តីពី ការគ្រប់គ្រងការប្រមូលពន្ធប្រថាប់ត្រា របស់អគ្គនាយកដ្ឋានពន្ធដារ ក្រោមអធិបតីភាពរបស់ឯកឧត្តម **គន់ វិបុល** ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ ព្រមទាំងវត្តមានចូលរួមរបស់ឯកឧត្តមអគ្គនាយករង នៃអគ្គនាយកដ្ឋានពន្ធដារ ទទួលបន្ទុក លោកប្រធាន-អនុប្រធាន នាយកដ្ឋានច្បាប់ វិវាទ និងស្ថិតិ លោកប្រធានសាខាពន្ធដារខេត្ត-ខណ្ឌទាំងអស់ ព្រមទាំងមន្ត្រីពាក់ព័ន្ធនឹងកិច្ចការប្រមូលពន្ធប្រភេទនេះជាច្រើនរូប ផងដែរ។

កិច្ចប្រជុំនេះផ្តោតជាសំខាន់លើការផ្សព្វផ្សាយ និងណែនាំមន្ត្រីពន្ធដារ ក្នុងការអនុវត្តខ្លឹមសារ នៃលិខិតលេខ ៣៦៧ សជណ ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៧ របស់រាជរដ្ឋាភិបាល ស្តីពីគោលការពាក់ព័ន្ធនឹងពន្ធប្រថាប់ត្រា លើការផ្ទេរសិទ្ធិកាន់កាប់អចលនទ្រព្យពុំបានចុះបញ្ជី (គ្មានប័ណ្ណកម្មសិទ្ធិ), ការពង្រឹងការគ្រប់គ្រងប្រមូលពន្ធ និងការពង្រឹងការផ្តល់សេវាជូនអ្នកជាប់ពន្ធ ដោយសមាជិកអង្គប្រជុំបានពិភាក្សាគ្នាយ៉ាងផុសផុល ក្នុងន័យស្វែងយល់ និងធានាបាននូវសង្គតិភាពនៃការ



© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ

អនុវត្ត ជាពិសេស ធ្វើយ៉ាងណាឱ្យការប្រមូលពន្ធប្រភេទនេះប្រព្រឹត្តទៅដោយរលូន។

ឯកឧត្តមប្រធានអង្គប្រជុំ ក៏បានណែនាំដល់នាយកដ្ឋានសាខាពន្ធដារខេត្ត-ខណ្ឌ និងមន្ត្រីក្រោមឱវាទដែលជាអ្នកអនុវត្តផ្ទាល់ក្នុងការប្រមូលពន្ធប្រភេទនេះ ដូចខាងក្រោម ៖

- ធ្វើការផ្សព្វផ្សាយបន្តឱ្យបានទូលំទូលាយ និងបានជ្រួតជ្រាប ដល់ប្រជាពលរដ្ឋគ្រប់មជ្ឈដ្ឋាន ដើម្បីយល់ដឹងពីនីតិវិធីនៃការបង់ពន្ធ

- ពង្រឹងប្រសិទ្ធភាព នៃការផ្តល់សេវាជូនអ្នកជាប់ពន្ធ ឱ្យបានល្អ ឆាប់រហ័ស ទាន់ពេលវេលា ស្របតាមប្រកាសលេខ ១១៤៦ សហវ.ប្រក ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៥ របស់ ក.ស.ហ.វ ស្តីពីការផ្តល់សេវាសាធារណៈរបស់អគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- ចៀសវាងឱ្យបានជាដាច់ខាត ការយកកម្រៃសេវាក្រៅផ្លូវការ ដែលមិនមានចែងក្នុងច្បាប់ បើពុំនោះទេ នឹងត្រូវទទួលរងនូវវិធានការរដ្ឋបាល និងវិធានការច្បាប់

- ពិនិត្យ កត់ត្រា តាមដានអំពីរំហូរឯកសារស្នើសុំបង់ពន្ធប្រថាប់ត្រារបស់អ្នកជាប់ពន្ធ ឱ្យបានច្បាស់លាស់ ចៀសវាងភាពយឺតយ៉ាវក្នុងការពិនិត្យសម្រេច លើឯកសារ របស់អ្នកជាប់ពន្ធ



© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ

- ណែនាំអ្នកជាប់ពន្ធ ឱ្យមកប្រកាសបង់ពន្ធដោយខ្លួនឯង ចៀសវាងការប្រើសេវាអ្នករត់ការមកបង់ពន្ធជំនួស ដែលជាហេតុនាំឱ្យខាតបង់ថវិកាច្រើន និងមានភាពយឺតយ៉ាវ។

ជាទីបញ្ចប់ ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល ប្រធានអង្គប្រជុំ បានវាយតម្លៃខ្ពស់ និងថ្លែងនូវអំណរគុណយ៉ាងជ្រាលជ្រៅចំពោះថ្នាក់ដឹកនាំគ្រប់អង្គភាពក្រោមឱវាទអគ្គនាយកដ្ឋានពន្ធដារ ដែលបាននិងកំពុងចូលរួមយ៉ាងសកម្មក្នុងការខិតខំ ប្រឹងប្រែងប្រមូលចំណូលរហូតទទួលបានលទ្ធផលយ៉ាងល្អប្រសើរ ដែលនេះគឺជាជោគជ័យរួមរបស់អគ្គនាយកដ្ឋានពន្ធដារ ព្រោះថា ប្រសិនបើមិនមានការចូលរួមពីគ្រប់អង្គភាពពាក់ព័ន្ធ ក្នុងការកែទម្រង់លទ្ធផលប្រមូលចំណូលពន្ធ នឹងមិនអាចសម្រេចទៅប្រកបដោយលទ្ធផលត្រចះត្រចង់បានឡើយ៕



© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ



© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ



© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ